# ពត៌មានប្រចាំថ្ងៃ

**MOI DAILY NEWS**

www.interior.gov.kh

## ពត៌មាន ប្រចាំថ្ងៃ របស់ ក្រសួងមហាផ្ទៃ

<u>ថ្ងៃទី ២៨ ដល់ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០០៥</u>

### ការតវ៉ារបស់ប្រជាពលរដ្ឋ និងអាជីវករផ្សារអូឡាំពិក

<u>រាជធានីភ្នំពេញ</u>

-នៅថ្ងៃទី២៧/៧/២០០៥ វេលាម៉ោង ១៤:៤០នាទី មានអាជីវករប្រមាណ ៥០នាក់ បានមកប្រមូលផ្តុំគ្នានៅមុខមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អោយជួយដោះស្រាយបញ្ហាអាជ្ញាធរខណ្ឌចំការមន រុះរើកន្លែងលក់ដូរនៅលើចិញ្ចើមផ្លូវ ។ អង្គការសិទ្ធមនុស្សបានទទួលពាក្យបណ្តឹង និងពាំនាំជូនរាជរដ្ឋាភិបាលដើម្បីដោះស្រាយ ។

-នៅថ្ងៃទី២៨/៧/២០០៥ វេលាម៉ោង ០៧:៣០នាទី នៅមុខសួនច្បារមុខវត្តបុទុមវត្តី មានប្រជាពលរដ្ឋប្រមាណ ១០០នាក់ (តំណាងអោយ ១៤៣គ្រួសារ) មកពីភូមិចំនួន ០២ ក្នុងឃុំ-ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង បានមកប្រមូលផ្តុំគ្នាសុំអោយរដ្ឋសភាជាតិជួយពិនិត្យ និងដោះស្រាយពាក្យបណ្តឹងរបស់ពួកគាត់ ដែលបានដាក់ជូនតាំងពីថ្ងៃទី៦/៧/២០០៥កន្លងមក ពីបញ្ហាដែលអាជ្ញាធរមូលដ្ឋានរំលោភយកដីស្រែ ចំនួន ២៥០ហិកតា លក់ទៅអោយឈ្មួញ ។ ការទាមទារខាងលើនេះត្រូវបានតំណាងខុទ្ទកាល័យរដ្ឋសភាជាតិ និង តំណាងប្រជាពលរដ្ឋចូលធ្វើការដោះស្រាយ ។

-នៅថ្ងៃទី២៨/៧/២០០៥ វេលាម៉ោង ១៨:៣៥នាទី នៅសួនច្បារមុខវត្តបុទុមវត្តី មានប្រជាពលរដ្ឋ ប្រមាណ ៩០នាក់ (តំណាងអោយ២៤០គ្រួសារ) មកពីភូមិចំនួន២ ក្នុងស្រុកស្នួល ខេត្តក្រចេះ ធ្វើការតវ៉ាសុំអោយរដ្ឋសភាជាតិជួយដោះស្រាយបញ្ហាក្រសួងបរិស្ថានហាមឃាត់ពួកគាត់មិនអោយកាប់ឆ្ការដីបង្កបង្កើនផល ។ សកម្មភាពនេះត្រូវបានតំណាងខុទ្ទកាល័យរដ្ឋសភាជាតិទទួលពាក្យបណ្តឹង និងសន្យាធ្វើការដោះស្រាយជូន ។

### ពត៌មានសន្តិសុខសង្គម

<u>រាជធានីភ្នំពេញ</u>

-កាលពីថ្ងៃទី២៧/៧/២០០៥ វេលាម៉ោង ២០:៤៥នាទី នៅចំណុចភូមិខ្វារ សង្កាត់ព្រែកលៀប មានជនល្មើស ០២នាក់ អាវុធខ្លី ០១ដើម ជិះម៉ូតូ ០១គ្រឿង បានស្ទាក់ប្លន់វាយនឹងស្ទាយកាំភ្លើងទៅលើជនរងគ្រោះឈ្មោះ ញ៉ែម ភារុណ ភេទប្រុស អាយុ ២០ឆ្នាំ យកបានម៉ូតូ០១គ្រឿង ។

<u>ខេត្តតាកែវ</u>

-នាថ្ងៃទី២៧/៧/២០០៥ វេលាម៉ោង ០២:០០នាទីរំលងអាធ្រាត នៅចំណុចផ្លូវលេខ២០៤ ក្នុងភូមិ ស្វាយខាងត្បូង ឃុំបាស្រែ ស្រុកអង្គបូរី មានជនល្មើស ០២នាក់ បានជិះម៉ូតូ ០១គ្រឿង ដេញបាញ់ជនល្មើសរងគ្រោះឈ្មោះ ជា ចាន់ផា ភេទប្រុស អាយុ ៣៣ឆ្នាំ (ដឹកសាំង០៥កានគេចពន្ធ) បណ្តាលអោយរបួសធ្ងន់ ។ កំលាំងសមត្ថកិច្ចកំពុងស្រាវជ្រាវកំណត់មុខសញ្ញា ដើម្បីចាប់ខ្លួន ។



អាស័យដ្ឋានៈ បន្ទប់លេខ១១៤ អគារទីស្តីការរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ
ទូរស័ព្ទ/ទូរសារៈ៨៥៥-២៣-៧២៦០៥២ Email:info@interior.gov.kh

ក្រុងព្រះសីហនុ

-នៅថ្ងៃទី២៦/៧/២០០៥ វេលាម៉ោង ២៤:០០នាទី នៅចំណុចភូមិ៤ សង្កាត់លេខ៤ ខណ្ឌមិត្តភាព មានជនល្មើស ០៣នាក់ បានប្លន់ និងវាយទៅលើជនរងគ្រោះឈ្មោះ សួន សម្បត្តិ ភេទប្រុស អាយុ៤០ឆ្នាំ (ម៉ូតូឌុប) បណ្តាលអោយរបួស រួចយកបានម៉ូតូគេចខ្លួន ។ ក្រោយកើតហេតុសមត្ថកិច្ចបានធ្វើការស្រាវជ្រាវរកឃើញ ម៉ូតូជនរងគ្រោះដែលជនល្មើសយកមកទុកចោលក្នុងគុម្ពោតព្រៃចម្ងាយ ៣០០ម៉ែត្រ ពីកន្លែងកើតហេតុ ។

-នាថ្ងៃទី២៨/៧/២០០៥ វេលាម៉ោង ១៨:៤០នាទី មានជនល្មើស ០៣នាក់ (មិនស្គាល់អត្តសញ្ញាណ) បានចូលប្លន់ និងចាប់រំលោភទៅលើជនរងគ្រោះឈ្មោះ សំ អ៊ូសារឿម ភេទស្រី អាយុ ៤៤ឆ្នាំ (បុគ្គលិកមន្ទីរសុខាភិបាលក្រុង) នៅភូមិ៣ សង្កាត់លេខ៤ ខណ្ឌមិត្តភាព ។ ក្រោយធ្វើសកម្មភាព រួចជនល្មើសយកបានសំភារៈសរុបជាទឹកប្រាក់ចំនួន ១៦០០ដុល្លារ រួចនាំបក្ខពួកគេចខ្លួនបាត់ ។ ករណីទាំងនេះត្រូវបានសមត្ថកិច្ចតាមដានស្រាវជ្រាវ និងស្វែងរកចាប់ខ្លួនជនល្មើស ដើម្បីផ្តន្ទាទោសតាមច្បាប់ ។

## លទ្ធផលកិច្ចប្រតិបត្តិការ

រាជធានីភ្នំពេញ :

-កំលាំងសមត្ថកិច្ចបានបង្ក្រាបករណី ប្លន់ប្រដាប់អាវុធ ០១ករណី ឃាត់ខ្លួន០២នាក់, ករណីលួចប្រជារាស្ត្រ ០៩ករណី ឃាត់ខ្លួន ១១នាក់, ករណីបង្ករបួសស្នាម ០២ករណី ឃាត់ខ្លួន ០៣នាក់, ករណីឆបោក ០១ករណី ឃាត់ខ្លួន ០២នាក់, ករណី ប្រើប្រាស់ថ្នាំញៀន០១ករណី ឃាត់ខ្លួនអប់រំ០២នាក់ និងករណីបង្ខាំងមនុស្ស និងគំរាមវាយអោយរបួស ០១ករណី ឃាត់ខ្លួន ០១នាក់ ។

ខេត្តកំពង់ចាម:

-អនុវត្តតាមដីកាតុលាការខេត្ត កំលាំងសមត្ថកិច្ចបានធ្វើការបង្ក្រាបករណីឃាតកម្ម ១ករណី ឃាត់ខ្លួន០១នាក់ និងករណីមនុស្សឃាត ០១ករណី ឃាត់ខ្លួន០៤នាក់ ។

ខេត្តកំពង់ឆ្នាំង:

-កំលាំងសមត្ថកិច្ចបានបង្ក្រាបករណីរំលោភ ០១ករណី ឃាត់ខ្លួន០១នាក់ និងករណីមនុស្សឃាត ០១ករណី ឃាត់ខ្លួន ០១នាក់ ។

ខេត្តកំពង់ស្ពឺ:

-កំលាំងសមត្ថកិច្ចបានបង្ក្រាបករណី ប្លន់ ០១ករណី ឃាត់ខ្លួន០១នាក់, ករណីប្រើប្រាស់អាវុធខុសច្បាប់ ០១ករណី ឃាត់ខ្លួន ០១នាក់ ដកហូតអាវុធ **CKC** ០១ដើម ។

ខេត្តកណ្តាល:

- អនុវត្តតាមដីកាតុលាការខេត្ត កំលាំងសមត្ថកិច្ចបានបង្ក្រាបករណី ករណីមនុស្សឃាត ០១ករណី ឃាត់ខ្លួន ០២នាក់ ។

( ប្រភពព័ត៌មានពីអគ្គស្នងការដ្ឋាននគរបាលជាតិ )



អាស័យដ្ឋាន៖ បន្ទប់លេខ១១៤ អគារទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ
ទូរស័ព្ទ/ទូរសារ:៨៥៥-២៣-៧២៦០៥២ Email:info@interior.gov.kh